# បុព្វកថា

ខ្ញុំសូមស្វាគមន៍យ៉ាងកក់ក្ដៅ ចំពោះការបោះពុម្ពផ្សាយ ក្នុងឆ្នាំទី១ លេខ២ របស់**ទស្សនាវដ្ដីស្រាវជ្រាវកម្ពុជាសម្រាប់ការអប់រំ និងស្ទែម** (Cambodian Journal of Education and STEM)។ ទស្សនាវដ្ដីស្រាវជ្រាវនេះ ត្រូវបានបោះពុម្ពអត្ថបទស្រាវជ្រាវជាភាសាខ្មែរ ដើម្បីចូលរួមចំណែកបង្កើនឯកសារស្រាវជ្រាវជាភាសាជាតិ ក្នុងគោលបំណងជំរុញ និងលើកកម្ពស់ការអភិវឌ្ឍការស្រាវជ្រាវនៅឧត្តមសិក្សាកម្ពុជា និងក្នុងប្រទេសកម្ពុជាទាំងមូល។

ក្រសួងអប់រំ យុវជន និងកីឡា បាននិងកំពុងជំរុញគ្រឹះស្ថានឧត្តមសិក្សាសាធារណៈ និងឯកជននៅកម្ពុជា ឱ្យបន្តចូលរួមយ៉ាងសកម្មក្នុងការកសាងប្រព័ន្ធអេកូឡូស៊ីសម្រាប់ការស្រាវជ្រាវ ដែលរួមមានការបង្កើត និងការអភិវឌ្ឍទស្សនាវដ្ដីស្រាវជ្រាវ។ ជាក់ស្ដែង ក្នុងអំឡុងពេលជាងមួយទសវត្សរ៍កន្លងមកនេះ ក្រសួងបានយកចិត្តទុកដាក់លើការលើកកម្ពស់ការស្រាវជ្រាវ និងការបោះពុម្ពផ្សាយ ដោយបានអនុវត្តគម្រោងលើកកម្ពស់គុណភាព និងសមត្ថភាពឧត្តមសិក្សា និងគម្រោងកែលម្អការអប់រំឧត្តមសិក្សា។ តាមរយៈគម្រោងទាំងពីរ ក្រសួងបានវិនិយោគលើការស្រាវជ្រាវដោយផ្ដល់មូលនិធិស្រាវជ្រាវលក្ខណៈប្រកួតប្រជែងស្រាវជ្រាវ ដល់គ្រូបង្រៀន សាស្ត្រាចារ្យ និងអ្នកស្រាវជ្រាវកម្ពុជា។

ក្រសួងក៏បាននិងកំពុងជំរុញការស្រាវជ្រាវផ្នែកស្ទែម និងកសិកម្ម តាមរយៈការលើកកម្ពស់ការផ្សារភ្ជាប់ការស្រាវជ្រាវទៅនឹងការធ្វើអាជីវកម្ម និងការអភិវឌ្ឍវិស័យឧស្សាហកម្ម ដោយបានវិនិយោគលើការបង្កើត ឬធ្វើទំនើបកម្មមន្ទីរពិសោធន៍ កសិដ្ឋានស្រាវជ្រាវ និងហេដ្ឋារចនាសម្ព័ន្ធស្រាវជ្រាវផ្សេងៗ ក្នុងគោលបំណងកសាង និងពង្រឹងប្រព័ន្ធអេកូឡូស៊ីស្រាវជ្រាវនៅឧត្តមសិក្សាកម្ពុជា។

កិច្ចការលើកកម្ពស់ការស្រាវជ្រាវ គឺស្របតាមយុទ្ធសាស្ត្រអប់រំឧត្តមសិក្សា គោលនយោបាយស្ដីពីទស្សនៈវិស័យឧត្តមសិក្សាឆ្នាំ២០៣០ និងចក្ខុវិស័យកម្ពុជាឆ្នាំ២០៣០ និង២០៥០ ក៏ដូចជានិន្នាការតំបន់ និងពិភពលោក។

ដើម្បីឆ្លើយតបទៅនឹងយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ របស់រាជរដ្ឋាភិបាលកម្ពុជា ក្រសួងអប់រំ យុវជន និងកីឡា នឹងបន្តធ្វើកំណែទម្រង់វិស័យអប់រំ ក្នុងគោលបំណងពង្រឹងគុណភាពអប់រំ និងលើកកម្ពស់ការស្រាវជ្រាវ ដើម្បីធានាថាប្រព័ន្ធអប់រំកម្ពុជាអាចបង្កើតមូលធនមនុស្ស ដែលអាចជំរុញកំណើនសង្គម-សេដ្ឋកិច្ច និងជួយកម្ពុជាសម្រេចបាននូវចក្ខុវិស័យរយៈពេលវែងរបស់ខ្លួន។

ក្នុងនាមក្រសួងអប់រំ យុវជន និងកីឡា ខ្ញុំសូមកោតសរសើរ និងវាយតម្លៃខ្ពស់ ចំពោះថ្នាក់ដឹកនាំក្រសួង ថ្នាក់ដឹកនាំអគ្គនាយកដ្ឋានឧត្តមសិក្សា ថ្នាក់ដឹកនាំ និងមន្ត្រីនៃនាយកដ្ឋានស្រាវជ្រាវវិទ្យាសាស្ត្រ ព្រមទាំងក្រុមប្រឹក្សាទស្សនាវដ្ដី ជាពិសេសនិពន្ធនាយក និពន្ធនាយករង និងក្រុមបច្ចេកទេសនៃទស្សនាវដ្ដីស្រាវជ្រាវកម្ពុជាសម្រាប់ការអប់រំ និងស្ទែម ដែលបានខិតខំប្រឹងប្រែង ប្រកបដោយការយកចិត្តទុកដាក់ និងការប្ដេជ្ញាចិត្តខ្ពស់ ក្នុងការរៀបចំបោះពុម្ពផ្សាយទស្សនាវដ្ដីស្រាវជ្រាវដ៏មានសារៈសំខាន់នេះឡើង។

ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា ការបោះពុម្ពផ្សាយទស្សនាវដ្ដីស្រាវជ្រាវនេះ នឹងផ្ដល់ចំណេះដឹងថ្មីៗ ដល់អ្នកអានទាំងអស់ ជាពិសេសនិស្សិត គ្រូបង្រៀន និងអ្នកស្រាវជ្រាវកម្ពុជា និងជួយលើកកម្ពស់វប្បធម៌ស្រាវជ្រាវនៅឧត្តមសិក្សាកម្ពុជា និងក្នុងប្រទេសកម្ពុជាបន្ថែមទៀត។

ថ្ងៃ ពុធ ១កើត ខែមិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២៣

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**